00228794

C26/I/30

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប |
| **ឈ្មោះសំណុំរឿង:** | **ខៀវ សំផន** |
| **ដាក់តម្កល់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ៨ តុលា ២០០៨ |
| **ភាគីអ្នកតម្កល់:** | ក្រុមការពារក្តី |
| **ភាសា:** | ភាសាដើមជាភាសាបារាំង បកប្រែក្រៅផ្លូវការជាភាសាខ្មែរ |
| **ប្រភេទឯកសារ:** | សាធារណៈ |

**ឯកសារបានទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 08 / OCT / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Tuy

---

## សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍

---

<u>បញ្ជូនដោយ:</u>

**មេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGÈS

<u>ជំនួយការ:</u>

កញ្ញា MOREAU Charlotte

អ្នកស្រី សេង សុជាតា

<u>បញ្ជូនទៅ:</u>

**អង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

# ជូនចំពោះអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម

1. ដើម្បីជំនុំជម្រះរឿងក្តីបណ្តឹងឧទ្ធរណ៍ ភាគីមួយក្នុងចំណោមភាគីនានាត្រូវប្តឹងទៅយុត្តាធិការលំដាប់ទីពីរ។ គឺផ្តើមចេញពីពាក្យបណ្តឹងនេះហើយដែលភាគីនេះមានទូវអំណាច និងធម្មានុរូបភាពរបស់ខ្លួន។ ភាគីនេះជាម្ចាស់ក្នុងការសម្រេចប្តឹងឧទ្ធរណ៍ ឬមិនប្តឹងឧទ្ធរណ៍ ហើយក៏នៅតែជាម្ចាស់លើសេចក្តីសម្រេចប្តឹងឧទ្ធរណ៍នេះផងដែរ នៅពេញអំឡុងពេលនៃនីតិវិធីដែលនាំទៅដល់សេចក្តីសម្រេច។ ដូច្នេះ នៅគ្រប់ពេលវេលាទាំងអស់ ភាគីនេះអាចសម្រេចបដិសេធចំពោះសិទ្ធិរបស់ខ្លួន ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ និងដកបណ្តឹងឧទ្ធរណ៍នេះ។ជម្រើសនេះជារបស់ភាគីហើយទោះជានៅក្នុងករណីណាក៏ដោយក៏ជម្រើសនេះមិនអាចធ្វើឲ្យខ្លួនខូចខាតប្រយោជន៍ឡើយ។

2. ច្បាប់ជាតិ និងច្បាប់អន្តរជាតិមិនមានចែងអំពីលក្ខខណ្ឌណាមួយ ដែលកំណត់អំពីសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ក្នុងការដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ ជនត្រូវចោទអាចដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនបាននៅគ្រប់ពេលវេលាទាំងអស់ដោយសេរី រហូតដល់ពេលមានសេចក្តីសម្រេចពីសំណាក់យុត្តាធិការបណ្តឹងឧទ្ធរណ៍ ដោយមិនចាំបាច់បញ្ជាក់អំពីហេតុផលណាមួយឡើយ។

## II. អង្គហេតុ និង នីតិវិធី

3. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងបានស្នើឲ្យចាប់ខ្លួន និងឃុំខ្លួនជាបណ្តោះអាសន្ននូវជនសង្ស័យចំនួនប្រាំរូប ដែលនៅក្នុងនោះមានលោក ខៀវ សំផន[1] ផងដែរ។

4. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ តាមរយៈដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លោក ខៀវ សំផន ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន[2] ។

5. នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាសម្រេចខាងលើនេះ[3]។

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ *ឯកសារតុលាការ D3*

[2] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ *ឯកសារតុលាការ C26*

6. សវនាការបណ្តឹងឧទ្ធរណ៍មួយបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨។ ដោយសារតែអវត្តមានការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ក្រុមការពារក្តីមិនអាចចូលរួមក្នុងសវនាការនោះបានទេ។ ដោយហេតុដូច្នេះ សវនាការក៏ត្រូវបានលើកទៅ "កាលបរិច្ឆេទមួយដែលនឹងកំណត់នៅពេលក្រោយ"[4]។

7. បួនខែបន្ទាប់មក អង្គបុរេជំនុំជម្រះក៏នៅតែមិនទាន់ប្រកាន់យកនូវសេចក្តីសម្រេចណាមួយ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នេះនៅឡើយ។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបង្គាប់មកក្រុមការពារក្តី ឲ្យធ្វើសេចក្តីកត់សម្គាល់របស់ខ្លួនស្តីពីសភាពនៃអង្គហេតុនេះ[5]។ នៅថ្ងៃទី២១ ខែសីហា ក្រុមការពារក្តីបានបញ្ជាក់ឡើងវិញអំពីគោលជំហររបស់ខ្លួន៖ ដរាបណាគ្មានការបកប្រែឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ទេនោះ "សហមេធាវីការពារក្តីនឹងមិនអាចធ្វើសហប្រតិបត្តិការជាមួយតុលាការបានទេ"[6]។

8. ហើយទន្ទឹមគ្នានោះ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ទាក់ទងនឹងការបកប្រែ[7]។ តាមការពិត ដីកានេះបានបដិសេធសំណើសុំបកប្រែរបស់លោក ខៀវ សំផន។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍[8]។

9. មកទល់ពេលនេះ បណ្តឹងឧទ្ធរណ៍នេះនៅតែមិនទាន់បានជំនុំជម្រះនៅឡើយ ហើយអង្គបុរេជំនុំជម្រះមិនទាន់ជជែកដោះស្រាយនៅឡើយ លើចំណុចដែលថា តើអង្គបុរេជំនុំជម្រះនឹងបើកសវនាការជាសាធារណៈឬអត់។

---

[3] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ *ឯកសារតុលាការ C26/I/3*

[4] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ឯកសារតុលាការ *C26/I/25*

[5] សេចក្តីបង្គាប់ដល់មេធាវីការពារក្តីស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន *ឯកសារតុលាការ C26/I/27*

[6] សេចក្តីជូនដំណឹងពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ ឯកសារតុលាការ *C26/I/28*

[7] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ *ឯកសារតុលាការ A190*

[8] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី ២២ កក្កដា ២០០៨ *ឯកសារតុលាការ A190/I/1*

10. រីឯបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន វិញ អស់រយៈពេលជិត១១ ខែ កន្លងទៅបន្ទាប់ពីការឃុំខ្លួនគាត់ អង្គបុរេជំនុំជម្រះទើបនឹងចេញសេចក្តីសម្រេចរបស់ខ្លួន៖ បណ្តឹងឧទ្ធរណ៍នឹងត្រូវបានដោះស្រាយតែដោយឈរលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីនានាតែប៉ុណ្ណោះ។ លោក ខៀវ សំផន អាចឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា នៅក្នុងរយៈពេល ៧ ថ្ងៃ[9]។

## III. បទបញ្ញត្តិគតិយុត្តិពាក់ព័ន្ធ

## ក- ច្បាប់កម្ពុជា

11. នៅចំពោះមុខ អ.វ.ត.ក សមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ត្រូវបានចែងដោយវិធាន ៧៣ នៃវិធានផ្ទៃក្នុង។ គឺជា "សមត្ថកិច្ចបន្ថែម" ដែលអនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះដោះស្រាយជាអាទិ៍ "លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចដែលបានចែងនៅក្នុងវិធាន ៧៤ ស្រាប់"[10]។

12. ដូច្នេះ អង្គបុរេជំនុំជម្រះអាចដោះស្រាយលើបណ្តឹងឧទ្ធរណ៍ដែលទាក់ទងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត តែប្រសិនបើភាគីណាមួយ (សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី) សម្រេចប្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។ នៅពេលនោះ ពាក្យបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងដោយ

---

[9] សេចក្តីបង្គាប់ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២ តុលា ២00៨ ឯកសារតុលាការ *C26/I/29*
ដោយសង្ខេប៖ អង្គបុរេជំនុំជម្រះយល់ឃើញថា សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តីឲ្យលោក ខៀវ សំផន (កាលពីខែធ្នូ) មិនបានលើកឡើងអំពីបញ្ហាការបកប្រែទេ ហើយដូច្នេះ ដោយអនុវត្តន៍តាមវិធាន ៧៥(៤) នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍គ្មានសិទ្ធិលើកឡើងអំពីចំណុចនេះនៅក្នុងពេលសវនាការឡើយ។ ដោយធ្វើដូច្នេះ អង្គបុរេជំនុំជម្រះពន្យល់បកស្រាយសេចក្តីកត់សម្គាល់ផ្ទាល់មាត់របស់មេធាវី ថាជាការបដិសេធមិនបន្តចូលរួមក្នុងសវនាការ។ ដោយហេតុថា បើតាមចៅក្រមអង្គបុរេជំនុំជម្រះ គោលជំហររបស់ក្រុមការពារក្តីតែងតែបង្អាក់ដំណើរប្រព្រឹត្តទៅនៃសវនាការនោះ អង្គបុរេជំនុំជម្រះ ១) សម្រេចជំនុំជម្រះក្តី ដោយឈរលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ២) បង្គាប់ឲ្យក្រុមការពារក្តី ដាក់ចម្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា ប្រសិនបើមាន។

[10] ដោយអនុលោមតាមមាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (តទៅនេះ ហៅថា "កនព") នៅក្នុងសាលាឧទ្ធរណ៍ មានសភាមួយដែលមានឈ្មោះថា សភាស៊ើបសួរ។ សភាស៊ើបសួរមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ។

គ្រាន់តែធ្វើសេចក្តីប្រកាសប៉ុណ្ណោះ[11] ហើយនិង "ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ប្រគល់ជូនទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវជូនដំណឹងភ្លាមដល់សហចៅក្រមស៊ើបអង្កេត និងត្រូវរក្សាទុកសំណុំឯកសារទាំងអស់នៃបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ។ ក្រោយពេលទទួលបានបណ្តឹងឧទ្ធរណ៍នេះ ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះត្រូវទទួលបានការជូនដំណឹងភ្លាម។"[12]

13.ដូច្នេះ នៅក្នុងលក្ខខណ្ឌដែលបណ្តឹងឧទ្ធរណ៍របស់ខ្លួនអាចទទួលយកបាននោះ ភាគី និងជាអាទិ៍ជនត្រូវចោទអាចជ្រើសរើសធ្វើការប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបានដោយសេរី និងប្តឹងទៅអង្គបុរេជំនុំជម្រះអំពីវិវាទរបស់ខ្លួន[13]។ ដូចគ្នាដែរ ភាគីអាចផ្លាស់ប្តូរសេចក្តីសម្រេចរបស់ខ្លួននេះបាន៖ ច្បាប់កម្ពុជាមិនមានខបញ្ញត្តិណាមួយដែលដាក់កម្រិតលើលទ្ធភាពនេះទេ។ ជនត្រូវចោទអាចជ្រើសរើសលទ្ធភាពទាំងនេះបានដោយសេរី និងដោយគ្មានការកម្រិតលើពេលវេលាអ្វីឡើយ[14]។

14.អវត្តមាននៃការដាក់កម្រិតនេះ គឺសមស្របទៅនឹងគោលបំណងចុងក្រោយនៃការប្តឹងឧទ្ធរណ៍៖ ផ្តល់ឱកាសដល់ភាគីដើមបណ្តឹងឧទ្ធរណ៍ឲ្យទទួលបានការជំនុំជម្រះរឿងក្តីរបស់ខ្លួន ពីសំណាក់តុលាការជាន់ខ្ពស់មួយ ក្នុងគោលបំណងធានា និងការពារសិទ្ធិរបស់ខ្លួន។ ដូច្នេះ នៅពេលដែល "សាលាឧទ្ធរណ៍ (...) បានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ [សាលាឧទ្ធរណ៍] មិនអាចដាក់ទម្ងន់ទោសជននោះបានទេ។ តុលាការអាចកែប្រែសាលក្រមបាន តែនៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។"[15]

15.ដូច្នេះ យោងតាមបទដ្ឋានច្បាប់កម្ពុជាដែលអាចអនុវត្តបាន សេចក្តីសម្រេចក្នុងការដកបណ្តឹងឧទ្ធរណ៍គឺជាសិទ្ធិរបស់ភាគីដើមបណ្តឹងឧទ្ធរណ៍។ ដោយហេតុដូច្នេះ យុត្តាធិការបណ្តឹងឧទ្ធរណ៍គ្មានអំណាចហើយក៏គ្មានសមត្ថកិច្ច ក្នុងការបដិសេធ ឬដាក់កម្រិត ឬក៏ធ្វើមិនដឹងមិនឮពីសេចក្តីសម្រេចនេះបានទេ។

---

[11] វិធាន ៧៥ នៃវិធានផ្ទៃក្នុង សូមមើលផងដែរមាត្រា ២៧២ នៃ កនព "បណ្តឹងឧទ្ធរណ៍ត្រូវធ្វើតាមការប្រកាសប្តឹងនៅក្រឡាបញ្ជីនៃតុលាការជាន់ដំបូង"

[12] វិធាន ៧៥ នៃវិធានផ្ទៃក្នុង, មាត្រា ២៧១ នៃ កនព៖ "បណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍", មាត្រា ២៥៧ "ត្រូវបើកឲ្យមានកាន់បញ្ជីបណ្តឹងឧទ្ធរណ៍ និងពាក្យសុំមួយនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ក្រឡាបញ្ជីនៃសភាស៊ើបសួរត្រូវតែឲ្យដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។"

[13] នៅក្នុងលក្ខខណ្ឌនៃភាពអាចទទួលយកបាន, វិធាន ៧៤-៣ នៃវិធានផ្ទៃក្នុង និង មាត្រា ២៦៧ នៃ កនព

[14] ដោយឡែក មាត្រា ២៥៩ នៃ កនព ចែងថា "គូភាគី និងមេធាវីត្រូវបានអនុញ្ញាតឲ្យជូនសារណារហូតដល់ពេលចាប់ផ្តើមបើកសវនាការ"។

[15] មាត្រា ៣៩៩ នៃ កនព

16. អនុលោមតាមមាត្រា ១២នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក “នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា”។ ទាក់ទងនឹងបញ្ហានេះ នីតិវិធីនៅក្នុងច្បាប់កម្ពុជាក៏មានសមិតភាព និងស្របតាមវិធាននៃនីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

## ខ- ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

17. លទ្ធភាពសម្រាប់ភាគីមួយក្នុងការដកបណ្តឹងឧទ្ធរណ៍ដែលខ្លួនបានប្តឹង ក៏ត្រូវបានទទួលស្គាល់ផងដែរដោយតុលាការព្រហ្មទណ្ឌអន្តរជាតិនានា។

18. ឧទាហរណ៍ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦ ការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (TPIY) បានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលធ្វើឡើងប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីរបស់លោក Pavle STRUGAR[16]។ នៅក្នុងការដកបណ្តឹងឧទ្ធរណ៍នេះ រដ្ឋអាជ្ញាមិនបានបង្ហាញការដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន ក្រោមទម្រង់ជាពាក្យសុំ ឬ សំណើសុំការអនុញ្ញាតដាក់ពាក្យសុំទេ ប៉ុន្តែក្រោមទម្រង់ជា “សេចក្តីជូនដំណឹងអំពីការដកពាក្យបណ្តឹង”។ ហើយរដ្ឋអាជ្ញាក៏បានបញ្ជាក់អះអាងយ៉ាងច្បាស់ថា សេចក្តីសម្រេចដកបណ្តឹងឧទ្ធរណ៍មិនស្ថិតនៅក្រោមការអនុញ្ញាត និងការព្រមព្រៀងពីសាលាឧទ្ធរណ៍ទេ។

19. នៅក្នុងរឿងក្តីដដែលនេះ ក្រុមការពារក្តីឲ្យលោក STRUGAR ក៏បានដាក់សេចក្តីជូនដំណឹងអំពីការដកបណ្តឹងផងដែរ ដើម្បីជូនដំណឹងទៅសាលាឧទ្ធរណ៍ថាខ្លួនដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន ហើយការដកបណ្តឹងឧទ្ធរណ៍នេះត្រូវមានអានុភាពលើនីតិវិធីភ្លាមៗ[17]។ ការអនុវត្តនេះពិតជាបានបង្កើតឡើង ហើយត្រូវបានគេអនុវត្តតាមនៅក្នុងរឿងក្តីអន្តរជាតិជាច្រើនទៀត[18]។

---

[16] TPIY ករណី *រដ្ឋអាជ្ញា c. STRUGAR,* IT-01-42-A, ការដកបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦។

[17] TPIYករណី *រដ្ឋអាជ្ញា c. STRUGAR* IT-01-42-A, **សេចក្តីជូនដំណឹងរបស់ក្រុមការពារក្តីអំពីការដកបណ្តឹងឧទ្ធរណ៍** ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៦។

[18] សូមមើលជាឧទាហរណ៍ TPIY ករណី *រដ្ឋអាជ្ញា c. Cermak et al,* IT-06-90-AR65.2 សេចក្តីប្រកាសដកបណ្តឹងឧទ្ធរណ៍ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨។

20. ដូច្នេះ នៅក្នុងច្បាប់អន្តរជាតិ លទ្ធភាពសម្រាប់ភាគីមួយក្នុងការដកបណ្តឹងឧទ្ធរណ៍ដែលខ្លួនបានប្តឹង មិនស្ថិតនៅក្រោមលក្ខខណ្ឌផ្នែកទម្រង់ ឬខ្លឹមសារណាមួយទេ។ លទ្ធភាពនេះមានអត្ថិភាពក្នុងលក្ខណៈជាសិទ្ធិ[19]។

## IV. មូលហេតុនៃការដកបណ្តឹងឧទ្ធរណ៍

21. ស្របតាមច្បាប់អនុវត្ត ក្រុមការពារក្តីរបស់លោក ខៀវ សំផន ត្រូវបានអនុញ្ញាតឲ្យដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនបាននៅគ្រប់ពេលវេលាទាំងអស់មុននឹងសេចក្តីសម្រេចមួយត្រូវបានធ្វើឡើង ដោយមិនចាំបាច់ពន្យល់ហេតុផលអ្វីឡើយ។ សេចក្តីសម្រេចដកបណ្តឹងឧទ្ធរណ៍នេះ មិនស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដោយឡែកណាមួយឡើយ។

22. ប៉ុន្តែ ដើម្បីឲ្យមានតម្លាភាពនិងភាពលម្អិតច្បាស់លាស់ ក្រុមការពារក្តីសូមបង្ហាញដោយសង្ខេបជូនទៅអង្គបុរេជំនុះជម្រះ អំពីមូលហេតុផ្សេងៗនៃសេចក្តីជូនដំណឹងនេះ។

23. រហូតមកទល់ពេលនេះ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនអស់រយៈពេលជិត១១ខែហើយ។ អង្គបុរេជំនុំជម្រះក៏ដឹងថា គាត់មានសុខភាពមិនល្អ ហើយគាត់កាន់តែចាស់ណាស់ទៅហើយ។[20] ដូច្នេះ នៅក្នុងរឿងក្តីរបស់គាត់ ភាពចាំបាច់ឲ្យមាននីតិវិធីដ៏ឆាប់រហ័ស គឺជាអាទិភាពដាច់ខាតមួយ។

24. ដោយឡែក នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ ពោលគឺជិត១០ខែបន្ទាប់ពីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចអំពីនីតិវិធីដែលត្រូវបន្ត ដើម្បីដោះស្រាយបណ្តឹងឧទ្ធរណ៍នេះ។ វាគ្មានអំណះអំណាងដើម្បីបញ្ជាក់អំពីភាពយឺតយ៉ាវនេះទេ។[21]

---

[19] សម្រាប់ជនត្រូវចោទ ឬ ជនជាប់ឃុំឃាំង លទ្ធភាពនេះគឺជាសិទ្ធិមួយ - ជាសារវន្ត - នៅពេលដែលលទ្ធភាពនេះស្ថិតនៅក្នុងក្របខណ្ឌនៃសិទ្ធិទូទៅក្នុងការរក្សាភាពស្ងាត់ស្ងៀម និងសិទ្ធិក្នុងការធ្វើ **ការការពារក្តីដ៏សមស្របបំផុត**។ សម្រាប់សហព្រះរាជអាជ្ញា លទ្ធភាពនេះស្ថិតនៅក្នុងក្របខណ្ឌនៃឱកាសក្នុងការចោទប្រកាន់ និងការធ្វើបណ្តឹងអាជ្ញា។

[20] សូមមើលជាអាទិ៍របាយការណ៍ផ្នែកជំនាញរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ *ឯកសារតុលាការ B9/I* របាយការណ៍វេជ្ជសាស្ត្រ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ ផ្នែកវេជ្ជសាស្ត្រ A - *ឯកសារតុលាការ B10,* របាយការណ៍ជំនាញផ្នែកប្រសាទសាស្ត្រ *ឯកសារតុលាការ B11*។

[21] សេចក្តីបង្គាប់ស្តីពីការបន្តនីតិវិធីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/29*។

25. នៅរយៈពេលមួយខែមុនការផុតកំណត់ដីកាសម្រេចឃុំខ្លួន អង្គបុរេជំនុំជម្រះបានសម្រេចថានឹងគ្មានការពិភាក្សាតទល់គ្នាទេ ហើយក៏គ្មានការការពារក្តីដ៏ពិតប្រាកដស្តីពីការឃុំខ្លួនបណ្តោះអាសន្នដែរ។ សហមេធាវីការពារក្តីមានភាពច្បាស់លាស់អំពីអសមត្ថភាពរបស់ខ្លួន ក្នុងការចូលរួមការពារកូនក្តីរបស់ខ្លួនយ៉ាងមានប្រសិទ្ធិភាព ប្រសិនបើគ្មានការបកប្រែនោះ។ នីត្យានុកូលភាពនៃគោលជំហររបស់ខ្លួននៅតែមានលក្ខណៈពេញលេញដដែល ព្រោះថាបណ្តឹងឧទ្ធរណ៍លើការបកប្រែមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ ដោយស្នើមកក្រុមការពារក្តីឲ្យឆ្លើយតបទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាការឃុំខ្លួននោះ អង្គបុរេជំនុំជម្រះបានសម្រេចធ្វើមិនដឹងមិនឮចំពោះសិទ្ធិរបស់ក្រុមការពារក្តី ទាក់ទងនឹងការបកប្រែ ហើយតាមពិតជាក់ស្តែង អង្គបុរេជំនុំជម្រះហាក់ដូចជាបានធ្វើការសម្រេចរួចទៅហើយលើបញ្ហានេះ។[22] ជាងនេះទៅទៀត អង្គបុរេជំនុំជម្រះបានយល់ព្រមយ៉ាងស្ងៀមស្ងាត់ថា ក្រុមការពារក្តីត្រូវបានផាត់ចេញ ឬពុំអាចចូលរួមយ៉ាងពិតប្រាកដនៅក្នុងនីតិវិធី។ ធ្វើដូច្នេះ អង្គបុរេជំនុំជម្រះពុំបានទទួលស្គាល់សិទ្ធិ និងផលប្រយោជន៍ជាមូលដ្ឋានរបស់លោក ខៀវ សំផន ព្រមទាំងភាពចាំបាច់នៃសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីប្រកបដោយយុត្តិធម៌ទេ។

26. ក្រុមការពារក្តីបានប្តឹងទៅអង្គបុរេជំនុំជម្រះអំពីបញ្ហានេះតាំងពីខែធ្នូ ឆ្នាំ២០០៧ ហើយអង្គបុរេជំនុំជម្រះមិនបានធ្វើការសម្រេចចំពោះសំណើនេះនៅឡើយ បើទោះបីជាមានភាពបន្ទាន់ដ៏ជាក់ច្បាស់ក៏ដោយ។ អង្គបុរេជំនុំជម្រះពិតជាមិនបានផ្តល់នូវមូលហេតុអាចយកជាការបានណាមួយឡើយ ដើម្បីពន្យល់ដោះសារអំពីភាពយឺតយ៉ាវនេះ ទោះបីនេះជាការរំលោភដ៏ជាក់ស្តែងទៅលើសិទ្ធិរបស់លោក ខៀវ សំផន ដើម្បីឲ្យរឿងក្តីរបស់ខ្លួនទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមស្របក៏ដោយ។

27. លោក ខៀវ សំផន មានសិទ្ធិទទួលបានការជំនុះជម្រះក្តីនៅក្នុងរយៈពេលមួយសមស្រប ដែលជាសិទ្ធិជាទូទៅមួយដែលរាប់បញ្ចូលនូវសិទ្ធិដោយឡែកមួយ ពោលគឺសិទ្ធិក្នុងការទទួលបានការស្តាប់យោបល់និងការសម្រេចសេចក្តីទៅលើសំណើរបស់ខ្លួន នៅក្នុងរយៈពេលដ៏សមស្របមួយ។ ការណ៍ដែលអង្គបុរេជំនុំជម្រះបានខកខានធ្វើការសម្រេចទៅលើចំណុចនេះ បានបណ្តាលឲ្យមានភាពយឺតយ៉ាវហួសហេតុមួយ ហើយនេះជាការរំលោភទៅលើសិទ្ធិជាសារវន្តរបស់ជនត្រូវចោទ។

28. សភាពនៃអង្គហេតុនេះក៏បានធ្វើឲ្យអង្គបុរេជំនុំជម្រះមិនអាចកាត់ក្តី ប្រកបដោយការយល់ដឹងយ៉ាងពេញលេញអំពីមូលហេតុនៃអង្គហេតុដែលទាក់ទងនឹងការឃុំខ្លួនផងដែរ ព្រោះថាជិត១០ខែហើយ

[22] សេចក្តីបង្គាប់ស្តីពីការបន្តនីតិវិធីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨ *ឯកសារតុលាការ C26/I/2*

បន្ទាប់ពីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងការឃុំខ្លួន អង្គហេតុដែលពាក់ព័ន្ធត្រូវបានផ្លាស់ប្តូរ ហើយការដោះលែងឲ្យមានសេរីភាពរឹតតែជាបញ្ហាបន្ទាន់បំផុត និងកាន់តែមានអំណះអំណាងទៀតដែរ។

29. ដូច្នេះ ក្រុមការពារក្តីគ្មានជម្រើសណាផ្សេង ក្រៅពីស្នើសុំទៅសហចៅក្រមស៊ើបអង្កេត ដើម្បីធានានូវសិទ្ធិរបស់លោក ខៀវ សំផន និងសុំឲ្យដោះលែងរូបគាត់ជាបន្ទាន់។ ធ្វើរបៀបនេះ ក្នុងប្រការដែលកើតមាន ក្រុមការពារក្តីក៏អាចរក្សាបានផងដែរនូវសិទ្ធិរបស់ខ្លួន ក្នុងការធ្វើបណ្តឹងឧទ្ធរណ៍យ៉ាងពិតប្រាកដលើបញ្ហានេះ។

## V. សេចក្តីសន្និដ្ឋាន

30. តាមរយៈសេចក្តីជូនដំណឹងនេះ សហមេធាវីការពារក្តីសូមប្រកាសដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលបានធ្វើឡើងប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅចំពោះមុខអង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧[23]។ ការដកបណ្តឹងឧទ្ធរណ៍នេះនឹងមានអានុភាពភ្លាមៗ។

ជំនួសសហមេធាវីការពារក្តី

លោកមេធាវី ស សូវាន

[23] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ *ឯកសារតុលាការ C26/I/3*